# II ទីស្ដីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

ភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៣

### អនុក្រឹត្យលេខ ០៤ អនក្រស្ទួន

- បានឃើញក្រឹត្យរបស់សម្ដេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតសាលាជាតិរដ្ឋបាល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ

**សំរេច**

មាត្រា ១ : សាលាជាតិរដ្ឋបាល ត្រូវឋិតក្រោមការគ្រប់គ្រងផ្ទាល់របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។ សាលាជាតិរដ្ឋបាលមានថ្នាក់ស្មើនាយកដ្ឋាន ។

មាត្រា ២ : តួនាទី ភារកិច្ចរចនាសម្ព័ន្ធរបស់សាលាជាតិរដ្ឋបាល ត្រូវកំណត់ឡើងវិញអោយបាន សមស្រប ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បណ្ដារដ្ឋមន្ត្រី នៃក្រសួងស្ថាប័នពាក់ព័ន្ធ និង នាយកសាលាជាតិរដ្ឋបាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា　　ហត្ថលេខា

សម្ដេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ**　　**ហ៊ុន សែន**